**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០២២ សហវ.ស

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការទូទាត់បំណុលថ្លៃទិញ ឬ ថ្លៃឈ្នួល ចលនវត្ថុ ឬ អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ

អនុលោមតាមមាត្រា១១នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ បានចែងថា "ត្រូវរំលាយចោលនូវរាល់កិច្ចសន្យាដែលទាក់ទងទៅនឹងការលក់ ឬការជួលចលនវត្ថុ ឬ អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងរាល់ការចាត់ចែងប្រើប្រាស់ទ្រព្យសម្បត្តិទាំងឡាយនោះ ក្នុងករណីដែលប្រធានស្ថាប័នបានធ្វើលិខិតតវ៉ាហើយ តែអ្នកទិញ អ្នកជួល ឬ អ្នកទទួលផលប្រយោជន៍នៅតែមិនគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀង ដូចជាការទូទាត់ថ្លៃលក់ ឬការបង់ថ្លៃឈ្នួលមិនបានគ្រប់ចំនួននិងទាន់ពេលវេលា "។ ក៏ប៉ុន្តែ មុននឹងឈានដល់ការរំលាយចោលកិច្ចសន្យា ត្រូវអនុវត្តការពិន័យ២ (ពីរ) ភាគរយក្នុងមួយខែ លើចំនួនទឹកប្រាក់ដែលមិនទាន់បានទូទាត់ជូនរដ្ឋ ចាប់ពី៦០ (ហុកសិប) ថ្ងៃក្រោយការកំណត់តទៅ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទបញ្ញត្តិខាងលើនេះ ដោយមិនអនុគ្រោះពន្យារពេលទូទាត់ទៀតឡើយ ។

កន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជូនដំណឹងដល់លោក លោកស្រី និងក្រុមហ៊ុនជាបន្តបន្ទាប់ ដើម្បីឱ្យទូទាត់បំណុលថ្លៃទិញ ឬថ្លៃឈ្នួលដែលនៅជំពាក់រដ្ឋឱ្យបានគ្រប់ចំនួននិងទាន់ពេលវេលា។ ព្រមគ្នានោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានពិនិត្យឃើញថា មានក្រុមហ៊ុនមួយចំនួនបានបំពេញកាតព្វកិច្ចបង់បំណុលថ្លៃទិញ ឬថ្លៃឈ្នួលបានគ្រប់ចំនួននិងទាន់ពេលវេលាតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀងនីមួយៗ និងមួយចំនួនទៀតនៅតែមិនបានទូទាត់បំណុលថ្លៃទិញ ឬថ្លៃឈ្នួលជូនរដ្ឋឡើយ ។

ក្នុងមូលហេតុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមជំរាបដល់លោក លោកស្រី និងក្រុមហ៊ុន ដែលនៅជំពាក់បំណុលថ្លៃទិញ ឬថ្លៃឈ្នួលចលនវត្ថុ ឬអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ សូមអញ្ជើញមកទូទាត់បំណុលថ្លៃទិញចូលគណនីលេខ ០២-៣៥.១២១១-T០២០ និងថ្លៃឈ្នួលចូលគណនីលេខ ០២-៣៥.១២១១-T០២៣ នៅនាយកដ្ឋានប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជាឱ្យបានចប់សព្វគ្រប់មុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០២ ជាកំហិត ។

ក្នុងករណីលោក លោកស្រីនិងក្រុមហ៊ុនមិនបានអញ្ជើញមកទូទាត់បំណុលតាមការកំណត់ទេនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងអនុវត្តយ៉ាងម៉ឺងម៉ាត់តាមច្បាប់ជាធរមាន និងតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងនីមួយៗ ដែលកំពុងតែមានសុពលភាព ដែលរួមមានទាំងការរំលាយចោលនូវកិច្ចសន្យាឬកិច្ចព្រមព្រៀងដែលទាក់ទងទៅនឹងការលក់ ឬការជួលចលនវត្ថុឬអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានវិធានការតឹងទារតាមផ្លូវច្បាប់ជាបន្តនិងធ្វើការផាកពិន័យតាមច្បាប់ឬតាមកិច្ចសន្យាឬកិច្ចព្រមព្រៀងបន្ថែមទៀត។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមទុកជាមុនថា លោក លោកស្រីនិងក្រុមហ៊ុនដែលបាននិងកំពុងជំពាក់បំណុលរដ្ឋទាំងអស់ មានស្មារតីភ្ញាក់រលឹកខ្ពស់ក្នុងការទូទាត់បំណុលឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលាដូចបានជំរាបជូនខាងលើនេះជាពុំខាន ដើម្បីជៀសវាងនូវការចាត់វិធានការជាយថាហេតុផ្សេងៗរបស់រដ្ឋ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រុមហ៊ុន ឬបុគ្គលដែលជំពាក់បំណុលថ្លៃទិញឬថ្លៃឈ្នួលទ្រព្យសម្បត្តិរដ្ឋ
- ឯកសារ

c ym appeal to leasee(left)